ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ៣៨៩
ចុះថ្ងៃទី០១-០៨-២០១៤
សាលដីកា
លេខ:០៦ ក្រ VI ក.ស
ចុះថ្ងៃទី២១-០៨-២០១៤

# តាងនាមប្រជារាស្ត្រខ្មែរ

## សាលាឧទ្ធរណ៍ ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ:០៦ក្រ ចុះថ្ងៃទី០៨-០២-១៩៩៣ បានបើកសវនាការជាសាធារណៈ នៅសាលាឧទ្ធរណ៍ នាថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៤ ដោយមាន ៖

**<u>សមាសភាពក្រុមប្រឹក្សា</u>**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**<u>តំណាងមហាអយ្យការ</u>**

លោក [redacted] ជាព្រះរាជអាជ្ញា

**<u>ក្រឡាបញ្ជីសវនាការ</u>**

លោក [redacted]

ដើម្បីជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍នៃរឿងព្រហ្មទណ្ឌលេខ:៦០៤ ចុះថ្ងៃទី២៨-០៦-២០១៤ រវាង៖

១-ជនជាប់ចោទឈ្មោះ [redacted]ចេង "ក្រៅឃុំ" ភេទស្រី អាយុ ៨៥ឆ្នាំ ជាតិខ្មែរ មុខរបរជក សាសនាព្រះពុទ្ធ។ ទីកន្លែងកំណើតនៅភូមិអង្កោល ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។ ឪពុកឈ្មោះ[redacted]"ស" ម្តាយឈ្មោះ[redacted]"ស" ប្តីឈ្មោះ[redacted]"ស" មានកូន ០១នាក់ ទោសពីមុនគ្មាន ជានីតិជន។

២-ជនជាប់ចោទឈ្មោះ[redacted]ហ៊ាន "ក្រៅឃុំ" ភេទស្រី អាយុ ៧៥ឆ្នាំ ជាតិខ្មែរ សាសនាព្រះពុទ្ធ។ ទីកន្លែងកំណើតនៅភូមិអង្កោល ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ ឪពុកឈ្មោះ[redacted]"ស" ម្តាយឈ្មោះ[redacted]"ស" ប្តីឈ្មោះ[redacted]"ស" មានកូន ០៤នាក់ ទោសពីមុនគ្មាន ជានីតិជន។

<u>ជាប់ចោទពីបទ:</u> លក់អចលនវត្ថុអ្នកដទៃ ប្រព្រឹត្តនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប កាលពីថ្ងៃទី០១-១០-២០០៧ បទល្មើសដែលមានចែងឲ្យផ្តន្ទាទោសតាមបញ្ញត្តិនៃមាត្រា ២៥៥ នៃច្បាប់ភូមិបាល។

៣-ជនជាប់ចោទឈ្មោះ[redacted]ាយ ហៅ ពែក "ក្រៅឃុំ" ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរនេសាទ សាសនាព្រះពុទ្ធ។ ទីកន្លែងកំណើតនៅភូមិអង្កោល សង្កាត់អង្កោល ខណ្ឌដំណាក់ចង្អើរ ក្រុងកែប ទីលំនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ ឪពុកឈ្មោះ[redacted]"រ" ម្តាយឈ្មោះ[redacted]"រ" ប្រពន្ធឈ្មោះ:[redacted]"រ" មានកូន ០៣នាក់ ទោសពីមុនគ្មាន ជានីតិជន។



Scanned by CamScanner

៤-ជនជាប់ចោទឈ្មោះ[redacted] ឯម "ក្រៅឃុំ" ភេទប្រុស អាយុ ៦៨ឆ្នាំ ជាតិខ្មែរ មុខរបរសមជិកក្រុមប្រឹក្សាឃុំ សាសនាព្រះពុទ្ធ។ ទីកន្លែងកំណើតនៅភូមិអង្គោល ឃុំភ្នំលាវទី២ ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ ឪពុកឈ្មោះ[redacted]ន "ស" ម្ដាយឈ្មោះ[redacted]ស" ប្រពន្ធឈ្មោះ[redacted]"ស" មានកូន ០៤នាក់ ទោសពីមុនគ្មាន ជានីតិជន។

<u>ជាប់ចោទពីបទ:</u> ក្លែងបន្លំលិខិត ប្រព្រឹត្តនៅភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប កាលពីថ្ងៃទី០១-១០-២០០៧ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមបញ្ញត្តិនៃមាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted]ហៀវ ភេទស្រី អាយុ៧៧ឆ្នាំ ជាតិខ្មែរ មានទីលំនៅភូមិត្រពាំងនៀល ឃុំឫស្សីស្រុកខាងលិច ស្រុកកំពង់ត្រាច ខេត្តកំពត ។

<u>ឯរឿងហេតុមានដូចតទៅ</u>

ឈ្មោះ[redacted]ហៀវ បានកាន់កាប់ដីមួយកន្លែងស្ថិតនៅភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប តាំងពីឆ្នាំ១៩៧៩មក។ នៅក្នុងឆ្នាំ១៩៨៣ ឈ្មោះ[redacted]ហៀវ បានចាកចេញទៅរស់នៅឯស្រុកកំពង់ត្រាច ខេត្តកំពត បានឲ្យឈ្មោះ[redacted]ពិសិដ្ឋ ជាអ្នកជួយថែ និងបង្កបង្កើតផលលើដីនោះ។ លុះមកដល់ឆ្នាំ២០០៧ ស្រាប់តែឈ្មោះ[redacted]ចេង និងឈ្មោះ[redacted]ហ៊ាន បានយកដីនោះលក់ទៅឲ្យឈ្មោះ[redacted]ឆាយ ហៅ ពែក និងបានឃុបឃិតគ្នាជាមួយឈ្មោះ [redacted] ឯម ក្លែងមេដៃលោកមេភូមិអង្គោលផ្ទេរសិទ្ធិកាន់កាប់ដីធ្លី ចុះថ្ងៃទី០១ ខែតុលា ឆ្នាំ២០០៧ ដើម្បីទិញយកដីនោះ។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១១ "ញ" ចុះថ្ងៃទី២៥-១២-២០១៣ របស់សាលាដំបូងខេត្តកំពត បានសម្រេចសេចក្ដី ដែលមានខ្លឹមសារដូចខាងក្រោម:

១.ផ្ដន្ទាទោស

ក.ឈ្មោះ[redacted]ចេង ភេទស្រី អាយុ ៨៥ឆ្នាំ ជាតិខ្មែរ មុខរបរជេក ។ ទីកន្លែងកំណើតនៅភូមិអង្គោល ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត ទីលំនៅបច្ចុប្បន្នៈភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។ ឪពុកឈ្មោះ[redacted] (ស) ម្ដាយឈ្មោះ[redacted](ស) ប្ដីឈ្មោះ [redacted]ស) មានកូន ០១នាក់។ ទោសពីមុនគ្មាន។ (ក្រៅឃុំ)

ដាក់ពន្ធនាគារកំណត់ ២ ឆ្នាំ ។ ដោយទោសនេះឲ្យព្យួរការអនុវត្តទាំងមូល យោងតាមមាត្រា១០៤ . ១០៧ នៃក្រមព្រហ្មទណ្ឌ។

ពីបទ លក់អចលនវត្ថុអ្នកដទៃ។ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុង មាត្រា ២៥៥ នៃច្បាប់ភូមិបាល។

ខ.ឈ្មោះ[redacted]ហ៊ាន ភេទស្រី អាយុ ៧៥ឆ្នាំ ជាតិខ្មែរ។ ទីកន្លែងកំណើតនៅភូមិអង្គោល ឃុំភ្នំលាវ ស្រុកកំពង់ត្រាច ខេត្តកំពត។ ទីលំនៅបច្ចុប្បន្នៈភូមិអង្គោល ឃុំអង្គោល ស្រុកដំណាក់ចង្អើរ ខេត្តកែប ។ ឪពុកឈ្មោះ[redacted](ស) ម្ដាយឈ្មោះ[redacted](ស) ប្ដីឈ្មោះ[redacted](ស) មានកូន ០៤នាក់។ ទោសពីមុនគ្មាន

បញ្ឈប់ការចោទប្រកាន់ ពីបទ លក់អចលនវត្ថុអ្នកដទៃ។ តាមមាត្រា ៧ ចំណុច១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

គ.ឈ្មោះ[redacted]ឆាយ ហៅ ពែក ភេទប្រុស អាយុ ៣៧ឆ្នាំ ជាតិខ្មែរ មុខរបរ នេសាទ។ ទីកន្លែងកំណើតនៅភូមិអង្គោល សង្កាត់អង្គោល ខណ្ឌដំណាក់ចង្អើរ ក្រុងកែប។ ទីលំនៅបច្ចុប្បន្នៈភូមិអង្គោល ឃុំអង្គោល



Scanned by CamScanner

ស្រុកដំណាក់ចង្អើរ ខេត្តកែប។ឪពុកឈ្មោះ[redacted] សិ (រ) ម្ដាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ[redacted] (រ) មានកូន បីនាក់។ ទោសពីមុនគ្មាន ។ ក្រៅឃុំ

ឃ.ឈ្មោះ[redacted] ឯម ភេទប្រុស អាយុ ៦៨ឆ្នាំ ជាតិខ្មែរ មុខរបរសមាជិកក្រុមប្រឹក្សាឃុំ។ ទីកន្លែងកំណើតនៅភូមិអង្កោល ឃុំភ្នំលាវទី២ ស្រុកកំពង់ត្រាច ខេត្តកំពត។ ទីលំនៅបច្ចុប្បន្នៈភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប។ ឪពុកឈ្មោះ[redacted](ស) ម្ដាយឈ្មោះ[redacted] (ស) ប្រពន្ធឈ្មោះ[redacted](ស) មានកូនបួននាក់។ ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

ដាក់ពន្ធនាគារម្នាក់ៗកំណត់ ២ ឆ្នាំ ។ ដោយទោសនេះឲ្យព្យួរការអនុវត្តទាំងមូល យោងតាមមាត្រា ១០៤. ១០៧ នៃក្រមព្រហ្មទណ្ឌ។

ពីបទ ក្លែងបន្លំលិខិត។ ប្រព្រឹត្តនៅភូមិអង្កោល ឃុំអង្កោល ស្រុកដំណាក់ចង្អើរ ខេត្តកែប កាលពីថ្ងៃទី ០១-១០-២០០៧ បទល្មើសព្រហ្មទណ្ឌ និងទោសមានចែងក្នុង មាត្រា ៦២៦ និងមាត្រា ៦២៧ នៃក្រមព្រហ្មទណ្ឌ។

២.ឲ្យឈ្មោះ[redacted] ចេងឈ្មោះ[redacted]ឆាយ ហៅពែក និងឈ្មោះ[redacted]ឯម រួមគ្នាបង់សំណង និងជម្ងឺចិត្តជាប្រាក់មកឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ [redacted] ហៀវ ក្នុងម្នាក់ៗចំនួន ៣.០០០.០០០រៀល (បីលានរៀល)។ បណ្ដឹងទាមទារលើសពីនេះ បដិសេធចោល។

៣.សាលក្រមនេះជំនុំជម្រះ និងប្រកាសជាសាធារណៈចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ចេង ឈ្មោះ[redacted]ឆាយ ហៅពែក. ឈ្មោះ[redacted]ឯម និងដើមបណ្ដឹងរដ្ឋប្បវេណី។

ទុក្ខសិទ្ធប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញ ពាក្យបណ្ដឹងឧទ្ធរណ៍លេខៈ ៣៦ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤ របស់ឈ្មោះ[redacted]ឆាយ ឈ្មោះ [redacted]ឯម និងឈ្មោះ[redacted]ចេង ប្ដឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១១ "៣" ចុះថ្ងៃទី ២៥-១២-២០១៣ របស់សាលាដំបូងខេត្តកំពត ត្រង់សេចក្ដីសម្រេចទាំងមូល។

បានឃើញ របាយការណ៍រឿងព្រហ្មទណ្ឌលេខៈ៣៨៩ ចុះថ្ងៃទី០១-០៤-២០១៤ របស់ចៅក្រមរបាយការណ៍ សាលាឧទ្ធរណ៍។

បានឃើញ សេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ចុះថ្ងៃទី០៦ខែសីហា ឆ្នាំ២០១៤។

## នាពេលសវនាការ

-ប្រធានក្រុមប្រឹក្សាអានសង្ខេបរបាយការណ៍រឿងក្ដី

-ក្រោយពីបានស្ដាប់ចម្លើយរបស់ជនជាប់ចោទ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យគ្រប់ឯកសារ និងភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សាលាឧទ្ធរណ៍

យល់ឃើញថា:

-ពាក្យបណ្ដឹងឧទ្ធរណ៍លេខៈ ៣៦ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤ របស់ឈ្មោះ[redacted]ឆាយ ឈ្មោះ [redacted] ឯម និងឈ្មោះ[redacted]ចេង ប្ដឹងឧទ្ធរណ៍ នឹងសាលក្រមព្រហ្មទណ្ឌលេខៈ ១១ "៣" ចុះថ្ងៃទី ២៥-១២-២០១៣ របស់សាលាដំបូងខេត្តកំពត ត្រង់សេចក្ដីសម្រេចទាំងមូល ធ្វើឡើងហួសកំណត់ច្បាប់ យោងតាម



Scanned by CamScanner

មាត្រា ៤០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហេតុដូច្នេះបណ្តឹងឧទ្ធរណ៍របស់ជនជាប់ចោទខាងលើ សភាព្រហ្មទណ្ឌប្រកាសថា មិនអាចទទួលបាន ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១-ប្រកាសថា: ពាក្យបណ្តឹងឧទ្ធរណ៍លេខ:៣៦ ចុះថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១៤ របស់ជនជាប់ចោទឈ្មោះ[redacted]ឆាយ ឈ្មោ[redacted] ឯម និងឈ្មោ[redacted]ចេង មិនអាចទទួលយកបាន។

២-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២១-៨-២០១៤ ចំពោះមុខជនជាប់ចោទឈ្មោ[redacted]ាយ ហៅ ពែក, មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ, ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]ចេង បើកផ្លូវប្តឹងទាស់ និងសាទុក្ខក្នុងកំណត់ច្បាប់។

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted] | ហត្ថលេខា [redacted] |

**បានឃើញ**
ប្រធានក្រុមប្រឹក្សា

[redacted]

-បានចំលងត្រឹមត្រូវតាមច្បាប់ដើម-
ភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ ២០១៤
ក្រឡាបញ្ជី

[redacted]



Scanned by CamScanner